# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះបង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ធំៗលើពិភពលោក និងប្រទេសនៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍។

កំណើនសេដ្ឋកិច្ចនៅតាមបណ្ដាប្រទេសឧស្សាហកម្ម និងប្រទេសភាគច្រើននៅតំបន់អាស៊ីបូព៌ា បន្តឡើងចុះទៀតនៅត្រីមាសទី៣ ឆ្នាំ២០១១ ដោយសារភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក និងកំណើនហានិភ័យពីវិបត្តិបំណុលនៅតំបន់អឺរ៉ុប។ ទោះយ៉ាងនេះក្ដី ប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍បន្តមានដំណើរការសេដ្ឋកិច្ចល្អ។

នៅត្រីមាសទី៣ ឆ្នាំ២០១១ ផសស ពិតប្រចាំឆ្នាំ នៅម៉ាឡេស៊ីមានកំណើន ៥,៨% ធៀបនឹង ៥,៣% កាលពីមួយឆ្នាំមុន។ សេដ្ឋកិច្ចនៅវៀតណាម បន្តមានអត្រាកំណើនខ្លាំង ដល់ ៧,២% ក្នុងមួយឆ្នាំ ធៀបនឹង ៥,៧% កាលពីត្រីមាសមុន និងមានអត្រាប្រហាក់ប្រហែលគ្នានឹងកាលពីមួយឆ្នាំមុន។ ផសស នៅសិង្ហបុរីមានកំណើន ៥,៩% ធៀបនឹង ០,៩% កាលពីត្រីមាសមុនដែលជាអត្រាកំណើនទាបបំផុត ចាប់តាំងពីពេលផ្ទុះវិបត្តិហិរញ្ញវត្ថុសាកលមក។ សេដ្ឋកិច្ចនៅចិន បន្តមានកំណើន ៩,១% ឬធ្លាក់ចុះបន្តិចបើធៀបនឹងត្រីមាសមុន ឬត្រីមាសដូចគ្នាឆ្នាំមុន។ កំណើន ផសស នៅហុងកុង ធ្លាក់មកត្រឹម ៤,៣% ធៀបនឹង ៦,៨% កាលពីមួយឆ្នាំមុន ហើយ ផសស នៅកូរ៉េខាងត្បូងធ្លាក់មកត្រឹម ៣,៤% ធៀបនឹង ៤,៥% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅតៃវ៉ាន់ ធ្លាក់មកត្រឹម ៣,៤% ធៀបនឹង ៩,៨% កាលពីមួយឆ្នាំមុន។

ប្រទេសឧស្សាហកម្មធំៗ បន្តប្រយុទ្ធនឹងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ច ដើម្បីកសាងទំនុកចិត្តរបស់អតិថិជន និងវិនិយោគិនឡើងវិញ។ ក្រុម ១២ប្រទេស ក្នុងតំបន់អឺរ៉ូ (Euro-12) កំពុងដោះស្រាយវិបត្តិបំណុល ក្នុងពេលដែលកំណើន ផសស ពិត មានត្រឹម ១,៤% នៅត្រីមាសទី៣ ឆ្នាំ២០១១ ធៀបនឹង ១,៩% កាលពីមួយឆ្នាំមុន។ យន្តការសម្របសម្រួលស្ថិរភាពហិរញ្ញវត្ថុអឺរ៉ុប (The European Financial Stability Facility) ត្រូវបានបង្កើតឡើង ដើម្បីផ្ដល់មូលនិធិសង្គ្រោះបណ្ដោះអាសន្នបន្ទាប់ពីការសង្គ្រោះប្រទេសក្រិចលើកទី១ នៅពាក់កណ្ដាលឆ្នាំ២០១០។ និទស្សន៍សេដ្ឋកិច្ចនៅជប៉ុន នៅតែបង្ហាញពីក្ដីបារម្ភដដែល ដោយសារប្រទេសនេះពុំមានកំណើនអ្វីសោះនៅត្រីមាសទី៣ ឆ្នាំ២០១១ នេះ បើធៀបនឹងកាលពីឆ្នាំមុន។ ប្រទេសជប៉ុន កំពុងបន្តជុសជុលការខូចខាតបង្កដោយគ្រោះមហន្តរាយស៊ូណាមិ ដែលបានបំផ្លិចបំផ្លាញដល់ផ្នែកខ្លះនៃការផ្គត់ផ្គង់វត្ថុធាតុដើម។ ជប៉ុន ក៏រងការប៉ះពាល់ផងដែរពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក វិបត្តិបំណុលក្នុងតំបន់អឺរ៉ូ និងប្រាក់យេនឡើងថ្លៃខ្ពស់ ដែលធ្វើឲ្យទំនិញនាំចេញរបស់ជប៉ុនមានថ្លៃខ្ពស់ជាងមុន ហើយអាចនាំឲ្យមានឱនភាពពាណិជ្ជកម្ម។ សហរដ្ឋអាមេរិក ទទួលបានលទ្ធផលសេដ្ឋកិច្ចល្អ ដោយកំណើន ផសស ប្រចាំឆ្នាំ ឡើងដល់ ១,៦% ធៀបនឹង ១,៥% កាលពីត្រីមាសមុន ប៉ុន្តែត្រូវប្រឹងប្រែងច្រើនថែមទៀត ដើម្បីឈានទៅដល់កម្រិតកំណើនដូចមុនពេលមានវិបត្តិវិញ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

អតិផរណានៅត្រីមាសទី៣ ឆ្នាំ២០១១ មាននិន្នាការកើនឡើង បើធៀបនឹងត្រីមាសមុន និងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ប្រទេសភាគច្រើន មានអាត្រាអតិផរណាខ្ពស់ជាងមុនដោយសារមួយចំណែក ការអនុវត្តគោលនយោបាយពង្រីកសេដ្ឋកិច្ច ដើម្បីទប់ទល់នឹងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក។ អតិផរណានៅកម្ពុជា ឡើងដល់ ៦,៧% ធៀបនឹង ១,៨% កាលពីមួយឆ្នាំមុន។ អតិផរណានៅវៀតណាម បន្តកើនឡើងដល់ ២២,៥% ធៀបនឹង ១៩,៤% នៅត្រីមាសមុន និង ៨,៤% កាលពីមួយឆ្នាំមុន។ ទំនិញវៀតណាមឡើងថ្លៃនេះ អាចដាក់សម្ពាធបន្ថែមលើថ្លៃទំនិញប្រើប្រាស់នៅកម្ពុជា ព្រោះកម្ពុជានាំចូលទំនិញច្រើនណាស់ពីវៀតណាម។ ក្នុងត្រីមាសដដែលនេះ អតិផរណានៅចិន ឡើងដល់ ៦,៣% ធៀបនឹង ៣,៣% កាលពីមួយឆ្នាំមុន រីឯអតិផរណានៅហុងកុង ឡើងដល់ ៦,៥% ធៀបនឹង ២,៣% នៅត្រីមាសដូចគ្នាឆ្នាំមុន។

នៅត្រីមាសទី៣ ប្រាក់រៀលធ្លាក់ថ្លៃ ១,២% ធៀបនឹងត្រីមាសមុន ដោយប្ដូរបាន ៤០៩៥,៦រៀល/ដុល្លារ US។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ធ្លាក់ថ្លៃ ០,៤% ទល់នឹងប្រាក់ដុល្លារUS ហើយប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ០,០៣% ប្រាក់ដុល្លារហុងកុងធ្លាក់ថ្លៃ ០,១% និង ប្រាក់អឺរ៉ូ ធ្លាក់ថ្លៃ ១,៤%។ នៅត្រីមាសនេះដែរ ដុល្លារសិង្ហបុរី ឡើងថ្លៃ ០,៨% ប្រាក់យន់ចិន ឡើងថ្លៃ ១,២% ហើយប្រាក់យេនជប៉ុន ឡើងថ្លៃ ៤,៦%។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០១១ ទំនិញប្រើប្រាស់សំខាន់ៗភាគច្រើន មាននិន្នាការធ្លាក់ថ្លៃ បើធៀបនឹងត្រីមាសមុន។ ពោត (US No. 2) ធ្លាក់ថ្លៃ ២,៨% មកត្រឹម ៣០២,៨ដុល្លារ/តោន ប្រេងឆា ធ្លាក់ថ្លៃ ៥,៩% មកត្រឹម ១០៧៩ដុល្លារ/តោន កៅស៊ូ (SMR 5) ធ្លាក់ថ្លៃ ៧,១% មកត្រឹម ៤៦១៧,៦ដុល្លារ/តោន ប្រេងឆៅ (OPEC spot) ធ្លាក់ថ្លៃ ៣,៨% មកត្រឹម ១០៨,៩១ដុល្លារ/ធុង សាំង (US Gulf Coast) ធ្លាក់ថ្លៃ ៥,២% មកត្រឹម ០,៧៤ដុល្លារ/លីត្រ។ នៅត្រីមាសនេះដែរ អង្ករ (Thai 100% B) ឡើងថ្លៃ ១៣% ដល់ ៥៨១,៣ដុល្លារ/តោន ហើយប្រេងម៉ាស៊ូត (low sulphur No 2) ឡើងថ្លៃ ២,០% ដល់ ០,៧ដុល្លារ/លីត្រ។ ទោះយ៉ាងណាក្ដី ផលិតផលទាំងអស់នេះបានឡើងថ្លៃ បើធៀបនឹងកាលពីមួយឆ្នាំមុនគឺ ពោត ឡើងថ្លៃ ៧១,៩% អង្ករ ឡើងថ្លៃ ២៤,១% កៅស៊ូ ឡើងថ្លៃ ៤៥,៤% សាំង ឡើងថ្លៃ ៤៤% និង ម៉ាស៊ូត ឡើងថ្លៃ ៤៤%។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 5.4 | 5.7 | 6.2 | 5.8 | 6.9 | 6.5 | 6.5 | 6.5 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -1.2 | 4.5 | 16.9 | 8.9 | 5.3 | 4.8 | 4.6 | 4.0 | 5.8 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | 0.8 | 4.0 | 17.4 | 18.7 | 10.5 | 12.0 | 8.3 | 0.9 | 5.9 |
| ថៃ | 4.8 | 4.9 | 2.6 | -2.8 | 5.8 | 12.0 | 9.2 | 6.7 | 3.8 | 3.0 | 2.6 | |
| វៀតណាម | 8.1 | 8.5 | 6.2 | - | - | 5.8 | 6.4 | 7.2 | 7.3 | 5.4 | 5.7 | 7.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 9.1 | 10.7 | 11.9 | 10.3 | 9.7 | 9.8 | 9.7 | 9.5 | 9.1 |
| ហុងកុង | 6.6 | 6.4 | 2.4 | -2.2 | 2.6 | 8.0 | 6.5 | 6.8 | 6.2 | 7.2 | 5.1 | 4.3 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | 0.4 | 6.1 | 8.1 | 7.1 | 4.5 | 4.8 | 4.2 | 3.4 | 3.4 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -1.3 | 8.4 | 14.6 | 12.9 | 9.8 | 6.9 | 6.5 | 4.9 | 3.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -4.7 | 0.1 | 0.6 | 1.7 | 1.9 | 2.0 | 2.5 | 1.6 | 1.4 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -4.7 | -1.4 | 5.5 | 3.5 | 5.0 | 2.2 | -1.0 | -1.0 | 0.0 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.6 | 2.8 | 2.9 | 2.3 | 2.8 | 2.3 | 1.5 | 1.6 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.2 | 6.7 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 2.78 | 2.6 | 3.6 | 4.4 | 6.2 | 6.3 | 6.8 | 5.9 | 4.7 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | -2.23 | -0.2 | 1.3 | 1.6 | 1.9 | 2.1 | 2.8 | 3.3 | 3.4 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | -0.4 | -0.3 | 0.9 | 3.1 | 3.4 | 4.0 | 5.2 | 4.7 | 5.5 |
| ថៃ | 4.7 | 2.2 | 5.5 | -2.1 | 1.9 | 3.7 | 3.3 | 3.3 | 2.0 | 3.0 | 4.1 | 4.1 |
| វៀតណាម | 7.7 | 8.3 | 23.3 | 2.6 | 4.6 | 7.5 | 9.0 | 8.4 | 10.9 | 12.8 | 19.4 | 22.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -1.26 | 0.7 | 2.1 | 2.7 | 3.3 | 4.7 | 5.1 | 5.7 | 6.3 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.9 | 1.3 | 1.9 | 2.6 | 2.3 | 2.9 | 4.0 | 5.1 | 6.5 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.0 | 2.4 | 2.7 | 2.6 | 2.9 | 3.6 | 4.4 | 4.2 | 4.8 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.3 | -1.3 | 1.3 | 1.1 | 0.4 | 1.1 | 1.3 | 1.6 | 1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | -0.34 | 0.4 | 1.1 | 1.5 | 1.7 | 2.0 | 2.5 | 2.7 | 2.7 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -2.2 | -2.0 | -1.2 | -0.9 | -0.9 | 0.1 | 0.0 | 0.3 | 0.2 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -1.6 | 1.4 | 2.3 | 1.8 | 1.2 | 1.3 | 2.1 | 3.5 | 3.8 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4163.10 | 4180.11 | 4209.02 | 4236.69 | 4122.58 | 4041.90 | 4044.89 | 4095.66 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 9472.44 | 9266.93 | 9132.00 | 8995.11 | 8965.70 | 8902.02 | 8593.94 | 8625.83 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.70 | 3.30 | 3.30 | 3.40 | 3.37 | 3.24 | 3.15 | 3.11 | 3.05 | 3.02 | 3.02 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 4.58 | 1.39 | 1.40 | 1.36 | 1.36 | 1.30 | 1.28 | 1.24 | 1.23 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 33.30 | 32.90 | 32.33 | 31.63 | 29.99 | 30.56 | 30.28 | 30.15 |
| វៀតណាម (ដុង) | 15994.00 | 16030.00 | 16382.00 | 18472.00 | 18825.67 | 18993.00 | 19485.00 | 19499.48 | 20273.83 | 20693.58 | 20699.60 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ័ន) | 7.97 | 8.03 | 6.94 | 6.83 | 6.83 | 6.77 | 6.77 | 6.66 | 6.58 | 6.50 | 6.42 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.76 | 7.78 | 7.77 | 7.76 | 7.79 | 7.78 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1167.77 | 1143.97 | 1166.04 | 1182.41 | 1132.85 | 1120.19 | 1084.27 | 1084.90 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 32.29 | 31.93 | 31.90 | 31.90 | 30.36 | 29.30 | 28.86 | 29.19 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.68 | 0.72 | 0.79 | 0.77 | 0.74 | 0.73 | 0.70 | 0.71 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 89.78 | 90.73 | 92.20 | 85.74 | 82.53 | 82.33 | 81.66 | 77.86 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 168.13 | 162.88 | 157.41 | 176.13 | 238.81 | 280.32 | 311.63 | 302.79 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 732.33 | 807.67 | 813.00 | 874.67 | 1108.00 | 1251.00 | 1147.00 | 1079.00 |
| កៅស៊ូ SMR 5 | 1996.30 | 2202.30 | 2586.30 | 2536.03 | 3105.90 | 3083.73 | 3175.97 | 4257.27 | 5278.03 | 4968.77 | 4617.57 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 569.00 | 565.67 | 461.33 | 468.33 | 531.00 | 528.25 | 514.33 | 581.3 |
| សណ្ដែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 390.43 | 372.68 | 370.95 | 406.88 | 480.24 | 537.24 | 525.66 | 513.98 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 73.86 | 75.73 | 77.00 | 74.91 | 84.17 | 100.70 | 113.31 | 108.91 |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 49.64 | 53.87 | 54.43 | 51.54 | 57.23 | 67.92 | 78.73 | 74.63 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 51.03 | 53.87 | 55.13 | 53.64 | 61.68 | 72.47 | 75.72 | 77.27 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ទោះបីបានជួបប្រទះនឹង គ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរបំផុតក្នុងមួយទសវត្សចុងក្រោយ ដែលបានបំផ្លិចបំផ្លាញដំណាំស្រូវនៅតាមតំបន់ជាច្រើនក្នុងប្រទេស ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសាកលក្តី ក៏សេដ្ឋកិច្ចកម្ពុជាជាទូទៅនៅឆ្នាំ២០១១ សម្រេចបានលទ្ធផលវិជ្ជមាន ហើយគេព្យាករណ៍ថា ផសស មានកំណើនដល់ប្រហែល ៦-៧%។ អនុមតិគម្រោងវិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់ ក្នុងត្រីមាសទី៣ ឆ្នាំ២០១១ កើន ៤% ធៀបនឹងត្រីមាសមុន ឬកើន ៧៥២,៩% ធៀបនឹងមួយឆ្នាំមុន ដល់ ២៧៤៨,៩លានដុល្លារ។ សញ្ញាងើបឡើងវិញនេះ អាចពិនិត្យឃើញជាអាទិ៍ក្នុងវិស័យឧស្សាហកម្ម ដោយអនុមតិវិនិយោគក្នុងវិស័យនេះ បានកើនឡើង ៤៩៩,២% ធៀបនឹងត្រីមាសមុន និង ៥៤៩,៤% ធៀបនឹងមួយឆ្នាំមុន។ វិនិយោគក្នុងវិស័យកាត់ដេរ កើន ១,២% ធៀបនឹងត្រីមាសមុន ដល់ ១០៩,៧លានដុល្លារ ដែលមួយផ្នែកបណ្តាលមកពីកំណើនយឺតក្នុងទីផ្សារទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ក្នុងវិស័យសេវាកម្ម ធ្លាក់ចុះ ៨៨,២% ធៀបនឹងត្រីមាសមុន មកត្រឹម ២៦៤,១ លានដុល្លារ ទោះបីជាចំនួនភ្ញៀវទេសចរបរទេស បានកើនឡើងក្តី (១៥,៤% ធៀបនឹងត្រីមាសមុន)។ អនុមតិគម្រោងវិនិយោគក្នុងវិស័យកសិកម្ម កើន ១០០% ធៀបនឹងត្រីមាសមុន ដល់ ៦,៩លានដុល្លារ វិស័យអចលនទ្រព្យ ក៏មានសញ្ញាងើបឡើងវិញដែរ ដោយតម្លៃសរុបនៃអនុមតិគម្រោងសាងសង់ កើន ២១៩,៧% ធៀបនឹងត្រីមាសមុន ឬ កើន ២១៥,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ២៤៧,៤លានដុល្លារ។

បរិមាណពាណិជ្ជកម្មសរុប នៅត្រីមាសទី៣ កើន ៨,២% ធៀបនឹងត្រីមាសមុន ឬ កើន ២៤,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ២២១៨,៧លានដុល្លារ។ ការនាំចេញសរុប កើនដល់ ១៤៥៥,៦លានដុល្លារ ដែលក្នុងនោះ សំលៀកបំពាក់មានចំណែកដល់ ៨៨,៣%។ គោលដៅនាំចេញសំខាន់ៗ រួមមាន សហរដ្ឋអាមេរិក សហភាពអឺរ៉ុប អាស៊ាន និងជប៉ុន។ បើធៀបនឹងត្រីមាសមុន ការនាំចេញទៅសហរដ្ឋអាមេរិក កើន ៣២,៧% (១៦,៤% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦១៩,៤លានដុល្លារ ការនាំចេញទៅសហភាពអឺរ៉ុប កើន ៣១,៨% (៦៦,០% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣៩៧,៥លានដុល្លារ ការនាំចេញទៅប្រទេសអាស៊ាន កើន ១២,០% (៦២,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ៤,៧លានដុល្លារ និងការនាំចេញទៅជប៉ុន កើន ៥៥,០% (៧០,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ៤៣,៤លានដុល្លារ។ ការនាំចេញកៅស៊ូ នៅតែរស់រវើកដោយបន្តកើនឡើង ១៥,៤% ធៀបនឹងត្រីមាសមុន ឬ ១២១% ធៀបនឹងមួយឆ្នាំមុន ដល់ ៥៦,១លានដុល្លារ។ ការនាំចេញមានសន្ទុះខ្លាំងក៏ពិតមែន ប៉ុន្តែមានសញ្ញាបង្ហាញច្បាស់ថា កម្ពុជាត្រូវធ្វើពិពិធកម្មទីផ្សារ និងទំនិញនាំចេញរបស់ខ្លួន ដើម្បីត្រៀមទប់ទល់នឹងហានិភ័យនៃការប្រកួតប្រជែង ពីសំណាក់ប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត និងការធ្លាក់ចុះសេដ្ឋកិច្ចក្នុងប្រទេសគោលដៅនាំចេញនានា។ ការបង្កើនទំនិញនាំចេញទៅកាន់ប្រទេសចិន តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងកម្រិតតំបន់ គឺជាជម្រើសមួយដែលកម្ពុជាគួរសិក្សាស្រាវជ្រាវបន្ថែមទៀត។

នៅត្រីមាសទី៣ នេះដែរ ទំនិញនាំចូលសរុប ធ្លាក់ចុះ ១៧% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៦៣,១លានដុល្លារ ក្នុងនេះ ការនាំចូលសាំង ធ្លាក់ចុះ ៤,០% ដល់ ៧៣,៨លានដុល្លារ ហើយប្រេងម៉ាស៊ូត ធ្លាក់ចុះ ៨,៤% មកត្រឹម ១១៨,៩លានដុល្លារ។ ប្រទេសកម្ពុជា សម្រេចបានអតិរេកពាណិជ្ជកម្ម រហូតដល់ ៦៩២,៥លានដុល្លារ ដោយវាកើន ២២៤,៦% ធៀបនឹងត្រីមាសមុន ឬ ១២០,៤% ធៀបនឹងមួយឆ្នាំមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ១១,៦% ធៀបនឹងត្រីមាសមុន ឬ កើន ១៦,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ១៥៦៤,៣ពាន់លានរៀល ដែលក្នុងនេះមាន ៩៩,៩% ជាចំណូលចរន្ត។ ចំណូលពន្ធ កើន ១៩,៧% ធៀបនឹងត្រីមាសមុន ដល់ ១៣៦៧,៥ពាន់លានរៀល ខណៈដែលចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១៧,៣% មកត្រឹម ១៩៥,៥ពាន់លានរៀល។ ក្នុងត្រីមាសដដែល ចំណាយសរុប កើន ៤១,០% ដល់ ២០២៥,២ពាន់លានរៀល ក្នុងនេះមាន ៦៤,៤% ជាចំណាយចរន្ត។ ចំណាយលើបៀវត្សរ៍ កើន ៣២,៥% ដល់ ៥៣១,៦ ពាន់លានរៀល ហើយឧបត្ថម្ភធន និងជំនួយសង្គមកិច្ច កើន ៧៥,១% ដល់ ៤៥០,៩ពាន់លានរៀល រីឯចំណាយចរន្តផ្សេងៗទៀត កើន ៦១,៦% ដល់ ៣២១,៧ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០១១ អតិផរណា (ទំនិញគ្រប់មុខ) នៅរាជធានីភ្នំពេញ កើន ៦,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១០។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៨,២% ហើយថ្លៃដឹកជញ្ជូន កើន ៨,៧%។ ប្រាក់រៀល ធ្លាក់ថ្លៃ ១,៣% ទល់នឹងប្រាក់ដុល្លារអាមេរិក ដោយប្តូរបាន ៤០៩៥,៧រៀល/ដុល្លារ ចុះថ្លៃ ១,១% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១៣៥,២រៀល/បាត និងចុះថ្លៃ ១,០% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ១៩,៨រៀល/១០០ដុង។ មាស ឡើងថ្លៃ

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវ កញ្ញា អ៊ួន វិមល និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

១២,៧% ធៀបនឹង ត្រីមាសមុន ឬ ៣៨,៤% ធៀបនឹងមួយឆ្នាំមុន ដល់ ២០៤,៦ដុល្លារ/ជី។ ប្រេងម៉ាស៊ូត ឡើងថ្លៃ ៣,០% ដល់ ៤៩២៤,៥រៀល/លីត្រ និង សាំង ឡើងថ្លៃ ៣,៦% ដល់ ៥២៤៨,៤រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

ក្នុងត្រីមាសទី២ ឆ្នាំ២០១១ សាច់ប្រាក់ងាយស្រួលសរុប កើន ៨,៥% ធៀបនឹងត្រីមាសមុន ដល់ ២២.០០៧,៦ពាន់លានរៀល ដែលក្នុងនេះមាន ៨២,២% ជាទ្រព្យសកម្មបរទេសសុទ្ធ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ២២,១% ធៀបនឹងត្រីមាសមុន ឬ ១១៩% ធៀបនឹងមួយឆ្នាំមុន ដល់ ៣៩០៧,៧ពាន់លានរៀល។ ក្នុងត្រីមាសទី២ នេះដែរ រូបិយវត្ថុ កើន ១,២% ដល់ ៣៥៣៩,៨ពាន់លានរៀល ហើយរូបិយវត្ថុផ្សេងៗ កើន ១០,១% ដល់ ១៨.៤៦៧ពាន់លានរៀល។

## ស្ថានភាពភាពក្រីក្រ

អង្កេតជាទៀងទាត់របស់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្ហាញនូវនិន្នាការចម្រុះគ្នានៃប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ។ ពីខែមករា ដល់ វិច្ឆិកា ២០១១ ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ ៨ក្រុម (កម្មកររោងចក្រកាត់ដេរ អ្នកលីសែង កម្មករសំណង់មាន និងគ្មានជំនាញ អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប អ្នកបម្រើតុភោជនីយដ្ឋាន និងអ្នករើសអេតចាយ) បានកើនឡើង ប៉ុន្តែប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែតូចតាច និងអ្នកស៊ីឈ្នួលធ្វើស្រែ បានធ្លាក់ចុះ។

ប្រាក់ចំណូលប្រចាំថ្ងៃពិត របស់កម្មកររោងចក្រកាត់ដេរ ដែលជួយរួមចំណែកយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រតាមទីជនបទ បានកើនឡើង ១០% ដល់ ៨៥៧២រៀល នៅខែវិច្ឆិកា ២០១១ ធៀបនឹង ៧៧៨១រៀល កាលពីខែវិច្ឆិកា ២០១០ ដោយសារកំណើនការនាំចេញសំលៀកបំពាក់ និងការវិនិយោគក្នុងវិស័យនេះ។ អង្កេតបង្ហាញថា ចំណាយប្រចាំថ្ងៃជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ មានពី ៤៥៣៩រៀល ដល់ ៥០១៤រៀល ឬ កើន ១១% ដោយសារទំនិញឡើងថ្លៃ។ ជាមធ្យម កម្មកររោងចក្រកាត់ដេរ ជួលផ្ទះមួយនៅរួមគ្នាបីនាក់។ ៨២% នៃកម្មករឆ្លើយសម្ភាសន៍ បានប្រាប់ថា ពួកគេស្នាក់នៅក្នុងផ្ទះជួលរួមគ្នាជាមួយអ្នកមកពីភូមិជាមួយគ្នា។

ជាមធ្យម ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ មានចំនួន ១០.២៨៩រៀល/ថ្ងៃ ឬ កើន ៥៥% ធៀបនឹងមួយឆ្នាំមុន និង ៣៥% ធៀបនឹងកាលពីខែសីហា ២០១១។ ៦០% នៃអ្នករើសអេតចាយ បានឆ្លើយសម្ភាសន៍ប្រាប់ថា របស់អេតចាយបានធ្លាក់ថ្លៃ ប៉ុន្តែមាន ៣០% និយាយថា របស់អេតចាយវាឡើងថ្លៃ ហើយមាន ៧០% ប្រាប់ថា ប្រភពរបស់អេតចាយបានថយចុះ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប កើន ២៦% ក្នុងមួយឆ្នាំ ពី ១០.២៧៨រៀល ដល់ ១២.៩៧១រៀល។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ទាំងអស់ ជាអ្នករកចំណូលចិញ្ចឹមគ្រួសារដែលជាមធ្យម មានសមាជិកប្រាំនាក់។ មានអ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ តែ ៣% ដែលនិយាយថា ប្រាក់ចំណូលរបស់ខ្លួនអាចផ្គត់ផ្គង់គ្រួសារបាន រីឯ ៩៧% ទៀត ប្រាប់ថា វាគ្រាន់តែជាប្រាក់ចំណូលបន្ទាប់បន្សំប៉ុណ្ណោះ។ ក្នុងចំណោមអ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ទាំងអស់ មានប្រហែលពាក់កណ្តាលស្ថិតក្នុងអាយុពី ៤០ ទៅ ៥០ឆ្នាំ។

អង្កេតបានរកឃើញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ បានកើន ២៣% ដល់ ១៤.៩៣០រៀល ដែលជាតួលេខខ្ពស់បំផុត គិតតាំងពីពេលចាប់ធ្វើអង្កេតនៅឆ្នាំ២០០៤ មក ដោយសារសកម្មភាពសាងសង់បានកើនឡើង។ ក្នុងពេលធ្វើការក្នុងរាជធានីភ្នំពេញ កម្មករសំណង់ ៩៥% ស្នាក់នៅការដ្ឋានសំណង់តែម្តង។

ក្នុងចំណោមក្រុមពលករងាយរងគ្រោះ អ្នកលីសែងទទួលបានប្រាក់ចំណូលខ្ពស់លំដាប់ទី៣ ដល់ ១១.៤៩០រៀល/ថ្ងៃ។ កាលពីខែវិច្ឆិកា ២០១០ ពួកគេអាចរកចំណូលបានត្រឹមតែ ៩៩៦៥រៀល/ថ្ងៃ ប៉ុណ្ណោះ។ កម្មករលីសែង គឺជាក្រុមមានចំណាយប្រើប្រាស់ប្រចាំថ្ងៃខ្ពស់ជាងគេ និង មានជាប់បំណុលច្រើនជាងគេដែរ រហូតដល់ ១.៤៩០.០០០រៀលជាមធ្យម សម្រាប់អ្នកលីសែងឆ្លើយសម្ភាសន៍ប្រមាណ ១៨% ដែលជាប់បំណុលគេនេះ។

ខណៈដែលក្រុមដទៃទៀត បានកើនប្រាក់ចំណូលប្រចាំថ្ងៃនោះ អ្នកលក់បន្លែតូចតាច និងអ្នកស៊ីឈ្នួលធ្វើស្រែ បែរជាថយចុះប្រាក់ចំណូលទៅវិញ។ ចំណូលរបស់អ្នកលក់បន្លែតូចតាច បានរួមចុះ ២០% មកត្រឹម ៧០៧៧រៀល/ថ្ងៃ ធៀបនឹង ៨៨២១រៀល/ថ្ងៃ កាលពីមួយឆ្នាំមុន។ ភាគច្រើននៃអ្នកលក់បន្លែតូចតាចឆ្លើយសម្ភាសន៍ បានសង្កេតឃើញនូវកំណើនចំនួនអ្នកលក់បន្លែ ក្នុងអំឡុងពេលបីខែចុងក្រោយនេះ។ ម្យ៉ាងទៀត ចំណាយប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេ បានកើន ០,៧% ធៀបនឹងមួយឆ្នាំមុន ឬ ០,៥% ធៀបនឹងខែសីហា ២០១១ ដល់ ៤១២៦រៀល។ ពួកគេត្រូវការទុនជាមធ្យម ៦៣.៦២៥រៀល/ថ្ងៃ ដើម្បីដំណើរការអាជីវកម្មរបស់ខ្លួន។

អ្នកស៊ីឈ្នួលធ្វើស្រែ ដែលបានសប្បាយរីករាយ ដោយមានកំណើនប្រាក់ចំណូលកាលពីអង្កេតលើកមុន បានថយចុះប្រាក់ចំណូលវិញមកត្រឹម ៤៥៥២រៀល ធៀបនឹង ៤៩១២រៀល កាលពីមួយឆ្នាំមុន។ ៦៥% នៃអ្នកឆ្លើយសម្ភាសន៍ គ្មានដីធ្វើកសិកម្មទេ រីឯ ៣២% មានដីកសិកម្មតិចជាងមួយហិកតា ហើយ ៣% មានដីកសិកម្មច្រើនជាងមួយហិកតា។ អ្នកស៊ីឈ្នួលធ្វើស្រែឆ្លើយសម្ភាសន៍ប្រមាណ ៣៥% មានសុទិដ្ឋិនិយមថា ប្រាក់ចំណូលរបស់ខ្លួននឹងកើនឡើងនៅត្រីមាសខាងមុខ ហើយ ៣០% និយាយថា ប្រាក់ចំណូលអាចនឹងធ្លាក់ចុះ។

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១១*

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92.0 | 615.0 | 165.7 | 41.4 | 278.0 | 36.7 | 4.1 | 0.0 | 6.9 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 818.5 | 247.7 | 54.5 | 44.3 | 87.7 | 67.1 | 413.5 | 2477.9 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *90.1* | *13.1* | *21.3* | *29.3* | *50.0* | *57.1* | *108.4* | *109.7* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 4432.0 | 89.5 | 121.6 | 0 | 1096.2 | 209.5 | 2229.2 | 264.1 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *3.78* | *14.0* | *0* | *1087.4* | *107.9* | *2221.9* | *264.1* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10,570.9 | 5865.5 | 502.9 | 217.5 | 322.3 | 1220.6 | 280.72 | 2642.7 | 2748.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -91.2 | -56.8 | 48.2 | 278.8 | -77.0 | 841.4 | 4.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | -44.5 | -59.8 | 452.0 | -16.6 | -71.3 | -44.2 | 1115.0 | 752.9 |

**Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 87.1 | 5.1 | 7.5 | 14.1 | 9.5 | 4.1 | 5.9 | 106.3 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 73.3 | 11.1 | 127.2 | 25.3 | 20.3 | 16.1 | 22.8 | 90.0 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 268.8 | 35.2 | 67.4 | 38.9 | 76.2 | 23.6 | 48.7 | 51.1 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 196.8 | 51.4 | 202.1 | 78.4 | 106.0 | 43.8 | 77.4 | 247.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -23.1 | 293.2 | -61.2 | 35.3 | -58.7 | 76.7 | 219.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | -82.4 | -71.6 | 224.4 | -14.2 | 58.7 | -14.8 | -61.7 | 215.6 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 371.5 | 260.9 | 288.3 | 383.7 | 427.4 | 286.9 | 335.3 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 999.7 | 312.2 | 276.6 | 293.8 | 321.4 | 351.0 | 319.6 | 364.5 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 2111.5 | 683.7 | 537.5 | 582.0 | 705.1 | 778.4 | 606.5 | 699.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 16.4 | -21.4 | 8.3 | 21.2 | 10.4 | -22.1 | 15.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | 0.5 | 9.9 | 15.8 | 19.4 | 20.0 | 13.9 | 12.8 | 20.2 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 2452.4 | 2922.8 | 3161.6 | 3209.5 | 2901.6 | 693.8 | 820.8 | 1045.4 | 1070.9 | 1017.6 | 1132.1 | 1455.6 |
| ក្នុងនេះៈ សម្លៀកបំពាក់ | 2352.8 | 2810.8 | 3050.2 | 3097.8 | 2565.3 | 625.5 | 716.9 | 938.3 | 942.7 | 880.5 | 964.2 | 1285.7 |
| *- សហរដ្ឋអាមេរិក* | 1555.6 | 1851.7 | 1959.9 | 1913.0 | 1512.6 | 380.5 | 416.7 | 531.9 | 524.8 | 464.5 | 466.7 | 619.4 |
| *- សហភាពអឺរ៉ុប* | 506.9 | 603.0 | 660.9 | 693.4 | 644.7 | 137.2 | 184.8 | 239.4 | 248.0 | 232.0 | 301.4 | 397.5 |
| *- អាស៊ាន* | 70.7 | 80.4 | 90.3 | 99.6 | 6.9 | 2.2 | 1.9 | 2.9 | 3.0 | 3.8 | 4.2 | 4.7 |
| *- ជប៉ុន* | 25.0 | 40.6 | 30.1 | 26.5 | 44.6 | 19.8 | 14.9 | 25.5 | 26.3 | 34.3 | 28.0 | 43.4 |
| *- ប្រទេសផ្សេងៗ* | 194.6 | 235.1 | 309.0 | 365.3 | 356.5 | 85.7 | 98.6 | 138.6 | 140.7 | 145.9 | 163.9 | 220.7 |
| កសិកម្ម | 61.3 | 59.7 | 55.6 | 44.6 | 73.1 | 21.2 | 27.2 | 44.9 | 72.3 | 74.0 | 167.9 | 98.9 |
| *- កៅស៊ូ* | 36.7 | 41.5 | 41.0 | 35.8 | 51.6 | 11.9 | 13.8 | 25.4 | 38.1 | 49.9 | 48.6 | 56.1 |
| *- ឈើ* | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 2.8 | 4.5 | 8.8 | 18.7 | 6.2 | 16.8 | 16.1 |
| *- ត្រី* | 10.1 | 5.9 | 3.2 | 2.3 | 4.0 | 0.8 | 0.7 | 0.5 | 0.8 | 0.6 | 0.4 | 1.4 |
| *- ផ្សេងៗ* | 4.2 | 3.7 | 2.7 | 3.1 | 14.0 | 5.7 | 8.2 | 10.2 | 14.7 | 17.3 | 31.3 | 25.3 |
| ផ្សេងៗ | 38.3 | 52.3 | 55.8 | 67.1 | 263.2 | 47.1 | 76.7 | 62.2 | 55.9 | 63.2 | 70.8 | 71.0 |
| ការនាំចូលសរុប | 2513.0 | 512.2 | 554.8 | 1010.9 | 2239.0 | 505.6 | 563.2 | 731.3 | 677.1 | 728.7 | 918.8 | 763.1 |
| ក្នុងនេះៈ សាំង | 40.2 | 38.8 | 58.7 | 70.1 | 91.2 | 28.8 | 22.4 | 27.6 | 30.5 | 62.0 | 76.7 | 73.8 |
| ម៉ាស៊ូត | 93.1 | 113.0 | 122.8 | 113.5 | 180.8 | 49.8 | 55.4 | 48.0 | 50.5 | 92.5 | 129.8 | 118.9 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 49.7 | 13.7 | 13.2 | 16.7 | 13.8 | 11.8 | 12.7 | 11.6 |
| ផ្សេងៗ | 2245.0 | 303.9 | 304.3 | 749.5 | 1917.3 | 413.3 | 472.2 | 638.9 | 582.3 | 562.4 | 699.6 | 558.8 |
| ជញ្ជីងពាណិជ្ជកម្ម | -60.6 | 2410.6 | 2606.8 | 2198.6 | 662.6 | 188.2 | 257.6 | 314.1 | 393.8 | 289.0 | 213.3 | 692.5 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 8.0 | 14.6 | 30.9 | 0.5 | -6.6 | 9.5 | 33.3 |
| ការនាំចេញសរុប | - | - | - | - | - | 5.9 | 18.3 | 27.3 | 2.4 | -5.0 | 11.3 | 28.6 |
| ការនាំចូលសរុប | - | - | - | - | - | -5.1 | 11.4 | 29.8 | -7.4 | 7.6 | 26.1 | -16.9 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 16.1 | 19.5 | 8.5 | 1.6 | -17.2 | 4.0 | 45.6 | 75.2 | 62.7 | 40.8 | 34.5 | 37.0 |
| ការនាំចេញសរុប | 16.3 | 19.2 | 8.2 | 1.5 | -9.6 | -2.3 | 46.8 | 68.5 | 63.5 | 46.7 | 37.9 | 39.2 |
| ការនាំចូលសរុប | 189.6 | -79.6 | 8.3 | 82.2 | 121.5 | -14.5 | -7.4 | 51.0 | 27.1 | 44.1 | 63.1 | 4.4 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១១ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 | 1400.5 | 1564.3 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 | 1378.6 | 1563.0 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 | 1142.3 | 1367.5 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 | 875.6 | 1095.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 | 266.7 | 272.3 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 | 236.3 | 195.5 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 | 10.6 | 18.6 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 | 130.0 | 138.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 | 95.7 | 37.9 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 | 21.9 | 1.3 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 | 1437.3 | 2025.2 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 | 579.8 | 721.0 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 | 857.5 | 1304.1 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 | 401.0 | 531.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 | 257.4 | 450.9 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 | 199.1 | 321.7 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 | -426.6 | -242.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 | -36.8 | -460.9 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 | 544.4 | 576.9 |

*Source: MEF website.*

### តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.3 | 6.7 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | -0.3 | 7.8 | 3.6 | 1.9 | 4.1 | 3.9 | 7.6 | 8.2 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 12.9 | 8.7 | 3.2 | 3.1 | 5.0 | 7.3 | 8.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4180.1 | 4209.0 | 4236.7 | 4122.6 | 4041.9 | 4044.9 | 4095.7 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 121.1 | 127.0 | 129.9 | 138.3 | 137.3 | 132.7 | 133.8 | 135.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 22.3 | 22.1 | 21.4 | 21.1 | 19.9 | 19.6 | 19.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 113.1 | 133.9 | 142.9 | 147.8 | 165.7 | 147.9 | 181.5 | 204.6 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 3170.9 | 3599.5 | 3835.1 | 3936.6 | 4066.1 | 4427.2 | 4784.6 | 4924.5 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3593.1 | 4163.0 | 4358.7 | 4415.5 | 4535.2 | 4750.1 | 5065.5 | 5248.4 |

*Sources: NIS, NBC and CDRI*

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10735.0 | 10345.0 | 13869.0 | 14655.0 | 15514.6 | 12610.9 | 16903.0 | 16697.9 | 17079.1 | 18099.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 | 3199.2 | 3907.7 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2120.4 | -2126.6 | -2252.7 | -2184.2 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10127.0 | 10532.0 | 11146.7 | 11859.1 | 12479.8 | 13331.2 | 13909.0 | 15290.6 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11311.0 | 11858.0 | 14912.0 | 16228.0 | 17234.5 | 18267.1 | 18887.8 | 19476.8 | 20278.3 | 22007.6 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 | 3497.2 | 3539.8 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 12139.0 | 13108.0 | 14086.0 | 15152.0 | 15826.1 | 16255.9 | 16781.1 | 18467.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 | 17.7 | 20.5 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 | 11.1 | 13.6 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 | 19.1 | 21.9 |

*Source: National Bank of Cambodia*

### តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2011 | | |
| | | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកជាក់ស៊ីក្លូ | 7469 | 8075 | 12,628 | 8091 | 8759 | 10633 | 8292 | 9783 | 9348 | -13.4 | 16.4 | 6.7 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 9965 | 11184 | 9861 | 10465 | 11554 | 5.6 | -0.6 | 16.0 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 8821 | 9149 | 8599 | 8405 | 7116 | 6.7 | 1.4 | -19.3 |
| អ្នករើសអេតចាយ | 4416 | 5422 | 4652 | 5857 | 6628 | 6931 | 8661 | 7557 | 10347 | 16.9 | 17.0 | 56.1 |
| អ្នកបម្រើភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 5448 | 6154 | 6066 | 5410 | 6271 | 12.7 | -15.8 | 15.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 4912 | 4806 | 5984 | 7345 | 4577 | -4.4 | 18.7 | -6.8 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 7944 | 8312 | 7950 | 8687 | 8620 | 6.1 | 2.6 | 8.5 |
| អ្នករត់ម៉ូតូឌុប | 8201 | 10634 | 15691 | 10685 | 10278 | 11444 | 10,630 | 11146 | 12971 | 3.5 | 5.6 | 26.2 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 9636 | 11291 | 9415 | 10526 | 9914 | 4.5 | 20.4 | 2.9 |
| កម្មករសំណង់មានជំនាញ | 10316 | 11154 | 12710 | 12487 | 12122 | 12487 | 12368 | 12676 | 15013 | 3.7 | 8.0 | 23.9 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000.*
*Source: CDRI*